# ជំងឺក្រៀមខ្មៅកន្ទុយស្លឹក

## ១. លក្ខណៈទូទៅរបស់ជំងឺ

ជំងឺក្រៀមខ្មៅកន្ទុយស្លឹក *(Colletotrichum leaf disease)* កើតមាននៅបណ្តាប្រទេសដាំដុះដំណាំកៅស៊ូជាច្រើនក្នុងពិភពលោកតាមកម្រិតស្រាលឬធ្ងន់ អាស្រ័យលើអាកាសធាតុ។ ជំងឺនេះ រាតត្បាតលើស្លឹកកៅស៊ូចាស់ និងកើតលើស្លឹកលាស់ថ្មីនៃដើមកៅស៊ូពេញវ័យក្រោយពេលរដូវជ្រុះស្លឹក។ ជំងឺក្រៀមខ្មៅកន្ទុយស្លឹកកើតមួយឆ្នាំពេញ ហើយកើតខ្លាំងនៅពេលចាប់ផ្តើមអាកាសធាតុសើម ដែលធ្វើឲ្យស្លឹកជ្រុះច្រើនចំពោះក្លូនងាយទទួលរងជំងឺ។ ជំងឺមានសភាពធ្ងន់ធ្ងរនៅពេលស្លឹកជ្រុះលើកទីពីរ ដោយផ្សិតនិងលក្ខខណ្ឌអាកាសធាតុសមស្រប ហើយវាក៏បានបាត់ទៅវិញនៅអំឡុងពេលខ្យល់បក់ពីទិសនិរតីទៅទិសឥសាន ដែលជាទូទៅវាអាចកើតឡើងនៅលើថ្នាលបណ្តុះកូនកៅស៊ូ និងនៅលើកៅស៊ូមិនទាន់ពេញវ័យ។

ពូជកៅស៊ូដែលងាយទទួលរងជំងឺរួមមាន៖ PB 86, RRII 300, RRII 105, RRII 118, RRII 208។

ពូជដែលទទួលរងជំងឺតិចតួចរួមមាន៖ RRIC 100, PB 217, PB 260 , RRIM 600,...។

## ២. រោគសញ្ញាជំងឺ

បង្កឡើងដោយផ្សិតឈ្មោះ *Colletotrichum gloeosporioides.* ដែលភាគច្រើនកើតនៅលើថ្នាលបណ្តុះកូន ច្បារពូជ និងដើមមិនទាន់ចៀរ។ លក្ខខណ្ឌសមស្របរបស់ជំងឺគឺមានភ្លៀងធ្លាក់ច្រើន សំណើមបរិយាកាសខ្ពស់ អំឡុងពេលស្លឹកនៅខ្ចី។ សីតុណ្ហភាពដែលអំណោយផលដល់ការលូតលាស់ និងរាតត្បាតនៃជំងឺក្នុងចន្លោះ ២៦-៣២$^{0}$C។ រោគសញ្ញាជំងឺច្រើនកើតលើស្លឹកខ្ចីដែលមានអាយុក្រោម១០ថ្ងៃ ហើយស្លឹកដែលទទួលរងនូវជំងឺនេះគឺចាប់ផ្តើមកើតចេញនៅចុងកន្ទុយស្លឹក។ ចំណុចតូចៗព័ណត្នោត និងរុំព័ន្ធដោយរង្វង់ព័ណលឿងផ្តុំគ្នាចាប់ផ្តើមក្រៀម និងបន្ទាប់មកធ្វើអោយស្លឹកនោះជ្រុះដោយទុកទងស្លឹកជាប់ដើម។ ស្លឹកដែលទទួលរងជំងឺនេះភាគច្រើនមានភាពជ្រួញនិងបន្ទាប់មករមួលមុននឹងវាចាប់ផ្តើមជ្រុះ។ ក្នុងករណីជំងឺធ្ងន់ធ្ងរ អាចបណ្តាលអោយជ្រុះស្លឹកជាច្រើនលើករហូតដល់ងាប់ត្រួយ មែក និងដើមទាំងមូល។

ប្រសិនបើជំងឺកើតលើស្លឹកចាស់ចាប់ពី ១០ថ្ងៃឡើង ស្លឹកមិនជ្រុះទេតែវាបន្សល់ទុកនូវ ស្នាមខេងខូងនៅលើផ្ទៃស្លឹក ធ្វើអោយស្លឹកបាត់បង់ទ្រង់ទ្រាយដើម។ កន្លែងរលួយមានរាងជារង្វង់ មូលមិនរាលដាល មិនជ្រុះ និងបង្កើតជាស្នាមអុចតូចៗ កន្ទួលព័ណត្នោត និងរុំព័ន្ធដោយរង្វង់ព័ណ លឿង។



*រូបភាពទី១៖ ជំងឺកើតនៅលើស្លឹកកៅស៊ូខ្ចី*



*រូបភាពទី២៖ ជំងឺកើតលើស្លឹកកៅស៊ូចាស់*

## ៣. ការការពារនិងការព្យាបាល

### ក. ការការពារ

- ប្រើប្រាស់ក្លូនដែលមានធន់ទ្រាំទៅនឹងជំងឺ

- ដាក់ជីបំប៉នដល់ដើមកៅស៊ូដែលរៀបនឹងចេញស្លឹក ដើម្បីឲ្យដើមកៅស៊ូមានកំលាំងក្នុងការជំរុញការដុះស្លឹកថ្មីលឿន

- ថ្នាលបណ្តុះកូនគួរតែបាញ់ថ្នាំការពារជំងឺដូចជា៖ ឌីតាន (Dithane M45) កម្រិត 0.5-1% ចំនួន២ គ.ក្រ/ហ.ត ឬប្រើកាបិនដាស៊ីម (Carbendazim) កម្រិត 0.2-0.3% ក្នុងមួយសប្តាហ៍ម្តង ឬប្រើ Maneb, Zineb កម្រិត 0.3-0.5%។

### ខ. ការព្យាបាល

**តារាងទី១៖ កម្រិតនៃការប្រើប្រាស់ថ្នាំព្យាបាលជំងឺលើថ្នាលកូននិងច្បារពូជ**

| ឈ្មោះថ្នាំ | បរិមាណទឹក (លីត្រ/ហិកតា) | បរិមាណថ្នាំ (ក្នុង១ហិកតា) | សំគាល់ |
|---|---|---|---|
| Dithane M45<br>(Mancozeb 800g/kg) | 200 | 3kg | ១ដំត្រ: ១គក្រ/ហិកតា |

| | | | |
|---|---|---|---|
| | | | ២ឆ័ត្រ: ២គក្រ/ហិកតា<br>៣ឆ័ត្រ: ៣គក្រ/ហិកតា |
| Kalonil<br>(Chlorothalonil750g/kg) | 200 | 3kg | ១ឆ័ត្រ: ១គក្រ/ហិកតា<br>២ឆ័ត្រ: ២គក្រ/ហិកតា<br>៣ឆ័ត្រ: ៣គក្រ/ហកតា |
| Carbendazime<br>(Carbendazim 50%) | 200 | 1L | អនុវត្តនៅពេលកើតជំងឺខ្លាំងបានតែ២-៣ដង/ឆ្នាំ |

- បាញ់ ១-២ ដង ក្នុងមួយសប្តាហ៍ អាស្រ័យទៅលើអាកាសធាតុ

- បាញ់ជាប់គ្នា ៣ដង ជាមួយ Dithane M45 និងលើកទី៤ ជាមួយ Kalonil ដើម្បីជៀសវាងការសាំថ្នាំជាមួយជំងឺ។

**ឧទាហរណ៍** Dithane M45, Dithane M45, Dithane M45, Kalonil

Dithane M45, Dithane M45, Dithane M45, Kalonil...

- ក្នុងករណីជំងឺកើតខ្លាំងត្រូវប្តូរថ្នាំពី Kalonil ទៅ Carbendazime វិញ។